ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៚✳៛៛៛

បណ្តុំអង្គការសមាគមសង្គមស៊ីវិល

លេខ ០១៨/ ២០២៣ ស.ជ

# ញត្តិគាំទ្រ

## គំនិតផ្តួចផ្តើមរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត ដើម្បីកែទម្រង់ «សិទ្ធិក្នុងការឈរឈ្មោះឱ្យគេបោះឆ្នោត»

បណ្តុំអង្គការសមាគមសង្គមស៊ីវិល សូមប្រកាសគាំទ្រទាំងស្រុងនូវគំនិតផ្តួចផ្តើមរបស់ **សម្តេចតេជោ ហ៊ុន សែន** ក្នុងការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត ដើម្បីកែទម្រង់ **«សិទ្ធិក្នុងការឈរឈ្មោះឱ្យគេបោះឆ្នោត»** ដោយចាត់ទុកថា ការកែទម្រង់នេះ គឺដើម្បីពង្រឹង និងលើកកម្ពស់ដំណើរការប្រជាធិបតេយ្យនៅកម្ពុជា ជាពិសេស ដើម្បីឱ្យនាគតអ្នកដឹកនាំ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលត្រូវជ្រើសរើសតាមរយៈការបោះឆ្នោត ត្រូវមានការទទួលខុសត្រូវខ្ពស់ចំពោះជាតិ និងប្រជាជន ហើយការទទួលខុសត្រូវនេះ ត្រូវចាប់ផ្តើមពីការអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវសិទ្ធិបោះឆ្នោតដែលជាករណីកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូបចំពោះប្រទេសជាតិ នៅក្នុងសង្គមប្រជាធិបតេយ្យ។

យោងតាមភាពចាំបាច់របស់កម្ពុជា ស្របតាមច្បាប់រដ្ឋធម្មនុញ្ញ មាត្រា៣៤ថ្មី កថាខណ្ឌចុងក្រោយដែលបានចែងថា " **បទបញ្ញត្តិដកសិទ្ធិបោះឆ្នោត និង សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់** " ខណៈពេលដែលមានចលនាវិទ្ធំសនារារាំង អំពាវពាវ មិនឱ្យពលរដ្ឋទៅចូលរួមការបោះឆ្នោតជាតិ នាពេលខាងមុខ និង ក្នុងគោលបំណងជម្រុញការអនុវត្តសិទ្ធិ និង កាតព្វកិច្ចរបស់ពលរដ្ឋគ្រប់រូប ដើម្បីធានាបាននូវការចូលរួមបោះឆ្នោតមួយប្រកបដោយសេរី ត្រឹមត្រូវ និង យុត្តិធម៌ និង បញ្ចៀសបាននូវ រាល់សកម្មភាព រារាំង វិទ្ធំសនា នានា ដែលនាំទៅដល់ការបាត់បង់សិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋ ។

ក្នុងនាមជាយុវជនសង្គមស៊ីវិលនៃបណ្តុំអង្គការសមាគមសង្គមស៊ីវិល សូមអំពាវនាវដល់ពលរដ្ឋខ្មែរគ្រប់រូប ពិសេសអ្នកដែលមានសិទ្ធិចូលរួមបោះឆ្នោត សុំទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នា នាថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខនេះកុំបីខាន ដើម្បីធានានូវកាតព្វកិច្ច ក្នុងការបោះឆ្នោតអាណត្តិទី៧ របស់ប្រទេសកម្ពុជា៕

ថ្ងៃច័ន្ទ ១០កេីត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣

បណ្តុំអង្គការសមាគមសង្គមស៊ីវិល

អាសយដ្ឋាន ទីស្នាក់ការកណ្តាលយុវជនសង្គមស៊ីវិល ផ្ទះលេខ ២១-២៣ ផ្លូវ១៨៩ សង្កាត់អូឡាំពិក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

**ព័ត៌មានបន្ថែម:** : 017907570 Telegram Email: ngosnewscambodia@gmail.com